**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Feb-2012, 15:29
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង សារី សុំការបញ្ជាក់ថា សេចក្តីសន្និដ្ឋានតទល់ មិនអាចត្រូវបានគេទាញយកពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ នៅពេលគាត់ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយរបស់គាត់

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS

Elisabeth SIMONNEAU FORT

លោក គង់ សំអុន

លោក Arthur VERCKEN

លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានដាក់សំណើមួយដែលមានចំណងជើងថា "សំណើរបស់ អៀង សារី សុំការបញ្ជាក់ពីការមិនអាចទាញសេចក្តីសន្និដ្ឋានដោយតទល់ពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប"[1] ("សំណើ") ដែលបានជូនដំណឹងដល់ភាគីនានាជាភាសាខ្មែរ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២។

២- តាមរយៈការដាក់ឯកសារនេះ មេធាវីការពារក្តី "ស្នើបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថាតើ សេចក្តីសន្និដ្ឋានដោយតទល់ អាច ហើយ នឹងត្រូវបានទាញយកពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប"[2] ដែរ ឬទេ។ ការបញ្ជាក់ដូច្នេះ ត្រូវបានគេអះអាងថានឹងធ្វើបាន បើសិនចាំបាច់ តាមស្មារតីដូចខាងក្រោម:

(ក) យោបល់ផ្សេងៗដែលបានធ្វើឡើង ដោយជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ លោក Tarik Abdulhak។ មេធាវីការពារក្តីឲ្យដឹងថា តាមរយៈយោបល់ដូច្នេះ គឺកសព បានអញ្ជើញឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ចំពោះសេចក្តីសន្និដ្ឋានតទល់ ចេញពីការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ[3], និង

(ខ) ការអញ្ជើញរបស់ចៅក្រម Lavergne ចំពោះជនជាប់ចោទ ខៀវ សំផន ដើម្បី "បញ្ជាក់", "ផ្តល់យោបល់" ឬ "ប្រតិកម្ម" ទៅនឹងសំណួរ និងឯកសារផ្សេងៗដាក់ចំពោះគាត់ បន្ទាប់ពីការសុំសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ ខៀវ សំផន"[4]។

៣- មេធាវីការពារក្តី ក៏បានកត់សម្គាល់ផងដែរថា អៀង សារី បានបញ្ជាក់ច្បាស់ហើយដោយគាត់បានសុំសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បន្ថែមទៅលើអ្វីដែលគេមើលឃើញថា ភាពចាំបាច់ក្នុងការបញ្ជាក់ពីគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះបញ្ហានេះ[5]។

---

[1] **E164**, "សំណើរបស់ អៀង សារី សុំការបញ្ជាក់ពីការមិនអាចទាញសេចក្តីសន្និដ្ឋានតទល់ពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប", ១៨ មីនា ២០១១។

[2] *ដដែលដូចខាងលើ* ត្រង់ទំព័រទី១។

[3] *ដដែលដូចខាងលើ* ។

[4] *ដដែលដូចខាងលើ* ។

៤- ចម្លើយតបនាពេលនេះត្រូវបានដាក់ ដើម្បីសុំការបញ្ជាក់ពីគោលជំហររបស់ កសព ទាក់ទិននឹងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខ អ.វ.ត.ក។ សហព្រះរាជអាជ្ញាស្វែងរក ជាពិសេស ដើម្បីកែតម្រូវទៅលើការកំណត់លក្ខណៈមិនត្រឹមត្រូវនៃគោលជំហរនោះធ្វើដោយមេធាវីការពារក្តី ដែលបង្កើតបានជាការសំអាងនៃសំណើ។

៥- ជំហររបស់សហព្រះរាជអាជ្ញាទាក់ទិននឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដោយហេតុមានភាពខុសគ្នាពីទម្រង់នៃសក្ខីកម្មផ្ទាល់មាត់ដែលបានបង្ហាញជូនមកទល់ពេលនេះដោយ ខៀវ សំផន នៅចំពោះមុខអង្គជំនុំជម្រះ គឺមាននិយាយលម្អិតនៅក្នុងការដាក់ឯកសារទន្ទឹមគ្នាមួយ ("សំណើរបស់ កសព ទាក់ទិននឹងស្ថានទម្ងន់នៃចម្លើយផ្ទាល់មាត់")[6]។ ជំហរនោះ បើនិយាយដោយសង្ខេបគឺថា ដូចដែល ខៀវ សំផន មិនបានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ ហើយបានជ្រើសយកការផ្តល់ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ដូច្នេះវាមិនបើកចំហរឲ្យគាត់បដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗ ដែលសួរដោយចៅក្រម និងភាគីនានាឡើយ[7]។ ការបដិសេធមិនឆ្លើយតបទៅនឹងការសួរដេញដោលណាមួយនឹងមានន័យថាចម្លើយផ្ទាល់មាត់របស់គាត់ មិនទំនងជាស្របនឹងស្ថានទម្ងន់នៃភ័ស្តុតាងសំខាន់ៗឡើយ ហើយសេចក្តីសន្និដ្ឋានដោយតទល់ អាចត្រូវបានទាញយកដោយអង្គជំនុំជម្រះប្រឆាំងនឹងរូបគាត់។

## II. ចម្លើយតប

៦- សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតបនៅក្នុងសវនាការ នៅចំពោះមុខ អវតក មិនដែលត្រូវបានការិយាល័យសហព្រះរាជអាជ្ញាធ្វើការតវ៉ាជំទាស់ទាល់តែសោះ ហើយជំហរណាមួយក៏មិនដែលត្រូវបានសំដែងឲ្យដឹង តាមរយៈតំណាងណាម្នាក់របស់ការិយាល័យនេះ ដើម្បីស្នើឲ្យមានសេចក្តីសន្និដ្ឋានតទល់ណាមួយដែលកើតចេញមកពីការអនុវត្តសិទ្ធិដែរ។

៧- ជនជាប់ចោទ អៀង សារី បានសំដែងឲ្យឃើញយ៉ាងច្បាស់នឹងដោយពិតប្រាកដនូវចេតនារបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយតប នៅក្នុងទូទាំងអម្លុងពេលនៃសវនាការជនុំជម្រះក្តីបច្ចុប្បន្ននេះ។ នេះ គឺទោះបីជាការសម្រេចចិត្តជ្រើសយករបស់គាត់ ក្នុងការប្រើប្រាស់នូវសិទ្ធិក្នុងការធ្វើសេចក្តី

---

[5] *ដដែលដូចខាងលើ* ។

[6] 'សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យផ្តល់យោបល់ ខៀវ សំផន អំពីស្ថានទម្ងន់នៃភ័ស្តុតាងនៃចម្លើយផ្ទាល់មាត់', ដែលនឹងត្រូវដាក់នៅសប្តាហ៍ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២។

[7] *ដដែលដូចខាងលើ*, កថាខ័ណ្ឌទី១-២។

ថ្លែងក្នុងពេលបើកសវនាការ ដែលគាត់បានអានជូនអង្គជំនុំជម្រះកាលពីថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ២០១១ នោះក៏ដោយ។ ការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់យ៉ាងត្រឹមត្រូវអំពីការសម្រេចចិត្តជ្រើសយកនេះ និងអំពីសិទ្ធិរបស់ជនជាប់ចោទដែលមិនត្រូវទទួលរងនូវផលវិបាកតទល់ណាមួយដែលជាលទ្ធផលនោះឡើយ។

៨- ផ្ទុយគ្នាពីជំហរដែលបានប្រកាន់យកដោយ អៀង សារី, ខៀវ សំផន បានលះបង់ចោលនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់ ដោយផ្ទុយទៅវិញ ជ្រើសរើសក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដែលធ្វើឈប់ៗ នៅក្នុងអម្លុងនៃដំណើរការនីតិវិធី មកដល់ពេលឥឡូវនេះមានការបដិសេធមិនឆ្លើយតបទៅនឹងសំនួរដែលសួរដេញដោលនានា។ ការខុសប្លែងគ្នារវាងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដែលបានធ្វើឡើងដោយ ខៀវ សំផន និងការអនុវត្តសិទ្ធិដើម្បីនៅស្ងៀមមិនឆ្លើយ គឺត្រូវបានឆ្លុះកាត់ជាលម្អិតដោយសំណើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលទាក់ទងនឹងទម្ងន់នៃការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នានា។

៩- មេធាវីការពារក្តីបានផ្អែកសំណើរបស់ខ្លួនដោយផ្អែកលើមូលដ្ឋាន ស្តីពីការបកស្រាយខុសដ៏ធំអំពីជំហររបស់ការិយាល័យសហព្រះរាជអាជ្ញាស្តីពីសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប ដូចដែលបានធ្វើឱ្យដឹងដោយជំនួយការជាន់ខ្ពស់របស់សហព្រះរាជអាជ្ញា លោក Abdulhak កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១២[8]។ នៅពេលអានដាច់ដោយឡែកអំពីអត្ថបទដែលដកស្រង់ខ្លីពីក្នុងសំណើសុំ អាចស្នើយោបល់ថា កសព បានស្នើសុំឱ្យអង្គជំនុំជម្រះទាញជាសេចក្តីសន្និដ្ឋានតទល់មួយចេញពីការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់ជនជាប់ចោទនោះផ្ទាល់តែម្តង ដូចដែរមេធាវីការពារក្តីធ្វើអំណះអំណាងនាពេលនេះ។ បើសិនសេចក្តីសន្និដ្ឋានត្រូវបានដកស្រង់សំដីទាំងស្រុងនោះ មុខជាឃើញច្បាស់ថា កសព ធ្វើឱ្យមានភាពខុសពីគ្នានូវសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប ខុសពីជំហរដែលបានប្រកាន់យកដោយ ខៀវ សំផន។ សេចក្តីសន្និដ្ឋានដែលជួសមុខឱ្យ កសព គឺច្បាស់ណាស់ ត្រូវបានផ្អែកលើមូលដ្ឋាននៃអង្គហេតុដែលថា ខៀវ សំផន មិនបានអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួននោះទេ៖

> *៧ **លោក អាប់ឌុលឡាក់ ថាវីកៈ***
> *៨ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម សូមអនុញ្ញាត*
> *៩ ដោយការបញ្ជាក់សង្ខេប ខ្ញុំជឿថាកាលពីខែធ្នូ លោកខៀវ សំផន*

---

[8] ឯកសារលេខ E1/26.1 , ប្រតិចារិក ចុះថ្ងៃទី១២ មករា ២០១២, ទំព័រ៦០:៧-៦១:៧។

*បញ្ជាក់ថា គាត់មិនបានប្រើសិទ្ធនៅស្ងៀមមិនឆ្លើយតបទេ*
*ដូចលោកប្រធានបានបញ្ជាក់ហើយប៉ុន្តែក្រោយមក*
*ការចង្អុលបង្ហាញក្នុងពេលសវនាការ ម្តងនោះគាត់បានឮពីភ័ស្តុតាង គាត់គួរ*
*ឆ្លើយតប។ យើងគិតថាមានន័យជាសក្ខីកម្ម ឆ្លើយនូវសំណួរទាំងពីរ*
*ពីចៅក្រម និងពីភាគី*

១០- ដូច្នេះ កសព បានធ្វើការកត់សម្គាល់ជាដំបូងថា ខៀវ សំផន បានលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ទាំងបានបញ្ជាក់យ៉ាងជាក់ច្បាស់ទៅកាន់អង្គជំនុំជម្រះ និងទាំងបានថ្លែងប្រកាសដោយផ្ទាល់មាត់ ដែលគាត់ធ្លាប់បានធ្វើរួចហើយនៅក្នុងអំឡុងពេលជំនុំជម្រះធ្វើសវនាការលើអង្គសេចក្តី។ ការបញ្ជាក់ត្រូវបានគេស្វែងរកធ្វើឡើងពាក់ព័ន្ធទៅនឹងការបដិសេធមិនឆ្លើយតបទៅនឹងសំណួរផ្សេងៗ ដោយភាគីនានា។ ការបញ្ជាក់បែបដូច្នេះត្រូវបានធ្វើឡើង ដើម្បីឲ្យមានសម្ពាធទៅលើសេចក្តីសន្និដ្ឋានដែលជិតនឹងកើតមានឡើងទៅលើវគ្គទីមួយនៃសវនាការនេះ។ នៅពេលនោះ គោលជំហររបស់ កសព ត្រូវបានធ្វើឡើងដោយពាក្យពេជន៍យ៉ាងប្រុងប្រយ័ត្នដូចតទៅ៖

*……… ។ ប៉ុន្តែ នៅចុងបញ្ចប់នៅផ្នែកនេះ នៅដំណាក់កាលទី១នៃសវនាការ*
*សវនាការដំបូងនេះ ប្រសិនបើលោក ខៀវ សំផន មានគោលជំហរថាពិនិត្យភស្តុតាងហើយគាត់ឆ្លើយ*
*គាត់នឹងបានឮភ័ស្តុតាងដំបូង ហើយបន្ទាប់មកត្រូវឆ្លើយតប ហើយគាត់*
*ស្នើសុំពេលសមស្របទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៅពេលនេះ*
*ឬក៏រហូតដល់ ឬក្រោយបញ្ចប់នៃសវនាការវគ្គទីមួយនេះ។*
*ដូច្នេះជំហររបស់សហព្រះរាជអាជ្ញា គឺថាតុលាការគប្បីសួរ*
*បញ្ជាក់គាត់*
*ប្រសិនបើគាត់បដិសេធក្នុងការផ្តល់សក្ខីកម្ម និងគ្រាន់តែប្រកាន់ជំហរថា*
*ថាតើគាត់នឹងប្រកាន់ជំហរ ថាគាត់នឹងឆ្លើយតបទេនៅពេលដំណើរការវិវត្តន៍ទៅមុខ។ នៅក្នុងករណីនេះ*
*គឺសហព្រះរាជអាជ្ញានឹងសន្និដ្ឋានទាក់ទងនឹង*
*ថាតើសេចក្តីសន្និដ្ឋានតទល់ដែលទាញចេញពីគោលជំហរនេះ*
*សូមអរគុណ*

១១- ខណៈដែលពិចារណាទាំងស្រុងទៅ វាច្បាស់លាស់ណាស់ថាសេចក្តីសន្និដ្ឋានរបស់ កសព គឺមានបំណងប្រាប់អង្គជំនុំជម្រះ និងជនជាប់ចោទឲ្យបានដឹងជាមុនអំពីតម្លៃជាភ័ស្តុតាង*ដ៏តិចតួចបំផុត* នៃសេចក្តីថ្លែងការផ្ទាល់មាត់របស់ជនជាប់ចោទ ដែលមិនអាចមានលទ្ធភាពត្រូវបានធ្វើពិសោធ តាមរយៈការសួរដេញដោល។ ទម្ងន់ដែលដាក់ទៅឲ្យសេចក្តីថ្លែងការណ៍បែបដូច្នេះ ហើយសេចក្តីសន្និដ្ឋានតទល់ណាមួយក៏ដោយដែលបានទាញចេញពីការបដិសេធ មិនឆ្លើយតបទៅនឹងការសួរដេញដោល

គឺមិនមានទាក់ទងទៅនឹងការអនុវត្តសិទ្ធិរបស់ជនជាប់ចោទ ក្នុងការនៅស្ងៀមមិនឆ្លើយតបទាល់តែសោះ។

១២- កសព ធ្លាប់បានបញ្ជាក់អះអាង និងយល់ព្រមទៅតាមសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទទាំងអស់ ក្នុងការនៅស្ងៀមមិនឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយនឹងធ្វើដូច្នេះជាបន្តទៀត[9]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[9] E101 សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម, ១៧ មិថុនា ២០១១, ERN 00708339-40, ទំព័រទី ៣ ("ជាការច្បាស់ណាស់ថា ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានមួយដែលនៅស្ងៀមមិនឆ្លើយបាននៅក្នុងសវនាការ")។ E51/5/3/1 ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩, ២១ មីនា ២០១១, ERN 00655302-37, ទំព័រទី ៣៥ ("ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ មិនទាមទារឲ្យ នួន ជា ឯកភាពទៅនឹង អង្គហេតុនានាជាមួយនឹងសហព្រះរាជអាជ្ញានោះទេ (ដែលជាការរំលោភយ៉ាងច្បាស់ទៅលើសិទ្ធិក្នុងការឋិតនៅស្ងៀមស្ងាត់")។ E101/3 សំណើរបស់សហព្រះរាជអាជ្ញា សុំការអនុញ្ញាតដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ពាក់ព័ន្ធទៅនឹងចេតនា របស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម, ៣ តុលា ២០១១, ERN 00743973-78, ទំព័រទី ៤ ("វាមិនមែនជាគោលជំហររបស់ សហព្រះរាជអាជ្ញាទេដែលថា បើជនជាប់ចោទសម្រេចចិត្តអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការនៅស្ងៀមមិននិយាយនៅពេលចាប់ផ្តើមសវនាការ គេ ចាំបាច់ត្រូវការពារគាត់មិនឲ្យផ្តល់សក្ខីកម្មនៅដំណាក់កាលក្រោយៗនៃសវនាការ")។